# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមហ៊ុនស្មាតសេីតស៍ ហ្គាមេនមេនូហ្វេកធឺរីង( ខេមបូឌា) ខូអិលធីឌី

## កិច្ចព្រមព្រៀង

### ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល៦១ថ្ងៃ

ថ្ងៃពុធ ១០ រោចខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០២៣ វេលាម៉ោង៩: ០០នាទីព្រឹក មានកិច្ចប្រជុំមួយនៅរោងចក្រស្មាតស៊ើតស៍ ហ្គាមេនមេនូហ្វេកធឺរីង( ខេមបូឌា) ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិ ស្រង់ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយ មានលោកស្រី ឈាន គ័រ ជានាយកក្រុមហ៊ុនបានបើកកិច្ចប្រជុំមួយជាមួយ បងប្អូនដែលជាប្រតិភូបុគ្គលិក ចំនួន ១៩នាក់ដែលតំណាងអោយកម្មករ កម្មកការិនី សរុប ៦៣៤នាក់។

ជាកិច្ចចាប់ផ្តើមលោកស្រី ឈាន គ័រ ជាប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ដល់ប្រតិភូបុគ្គលិក ទាំងអស់ដែលបានចូលរួម និងបានបើកកិច្ចពីភាក្សាអំពីការព្យួកិច្ចសន្យាការងាររបស់កម្មករ និយោជិត ចំនួន២១៣នាក់(ស្រី២០១នាក់)ក្នុងចំណោមកម្មករ និយោជិតសរុប ៦៣៤នាក់ (ស្រី៦៣៤នាក់) សម្រាប់រយៈពេល៦១ថ្ងៃ ដោយចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ ថ្ងៃទី១០ ខែ មករា ឆ្នាំ២០២៤ ដោយស្ថានភាពការបញ្ជាទិញរបស់អតិថិជនមានការធ្លាក់ចុះយ៉ាងខ្លាំង។

ក្រោយការពិភាក្សាគ្នា រវាងភាគីតំណាងក្រុមហ៊ុន និង ប្រតិភូបុគ្គលិក រួចមកភាគីទាំងពីរបានឯក ភាពផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិត៧៥ដុល្លារក្នុងអំឡុងពេលព្យួរ ៖

- ចាប់ពីថ្ងៃទី ១១ ដល់ ៣០ ខែ វិច្ឆិកា ឆ្នាំ២០២៣ ក្រុមហ៊ុនផ្តល់ជូន ៣០ដុល្លារ
- ចាប់ពីថ្ងៃទី ០១ ដល់ ៣១ ខែ ធ្នូ ឆ្នាំ២០២៣ ក្រុមហ៊ុនផ្តល់ជូន ៣០ដុល្លារ
- ចាប់ពីថ្ងៃទី ០១ ដល់ ១០ ខែ មករា ឆ្នាំ២០២៤ ក្រុមហ៊ុនផ្តល់ជូន ១៥ដុល្លារ

ប្រាក់ឧបត្ថមនេះ ក្រុមហ៊ុននឹងបើកជូនកម្មករនៅរៀងរាល់ថ្ងៃទី ១០ នៃខែនីមួយៗ។

ដើម្បីជាភស្តុតាងលើលិខិតស្នើរសុំព្យួរកិច្ចសន្យាការងាររយៈពេល៦១ថ្ងៃ ដែលចុះ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០២៣ យើងខ្ញុំទាំងអស់គ្នា ជាប្រតិភូពេញសិទ្ធ ទាំងអស់សូមផ្តិតមេដៃ ដូចខាងក្រោមនេះ។

*ប្រតិភូបុគ្គលិកប្រចាំរោងចក្រ*

*កំពង់ស្ពឺ.ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០២៣*

វី សីថា    ណើរ សារ៉ាត់    ឯម ធារ៉ា

SMART SHIRTS GARMENTS MANUFACTURING (CAMBODIA) Co.,Ltd. KINGDOM OF CAMBODIA

*លោកស្រី* **QIAN GE**

| | | | |
|---|---|---|---|
| ជឹម ស្រីណាក់ | សៀង សុជាតិ | ថន សំអាត | ម៉ែន មិនា |
| អ៊ួន ចាន់ធី | អឿន សារិត | ស៊ុំ ស្រីម៉ៅ | សាន់ គន្ធា |
| លន់ វីណា | ដើង សារី | | |

SMART SHIRTS GARMENTS MANUFACTURING (CAMBODIA) Co.,Ltd.
KINGDOM OF CAMBODIA